# កិច្ចព្រមព្រៀងបំពេញបន្ថែម
# រវាងអង្គការសហប្រជាជាតិ
# និង រាជរដ្ឋាភិបាលកម្ពុជា
# បន្ថែមទៅលើ
# កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ
# ទាក់ទងទៅនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា
# នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ
# ស្តីពីការរៀបចំសុវត្ថិភាព និងសន្តិសុខ

*ដោយហេតុថា* នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទាក់ទងទៅនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (តទៅនេះហៅថា "**កិច្ចព្រមព្រៀង**")

*ដោយហេតុថា* មាត្រា ២៤ នៃកិច្ចព្រមព្រៀងចែងថា រាជរដ្ឋាភិបាលកម្ពុជាត្រូវចាត់វិធានការគ្រប់គ្រាន់ និងមានប្រសិទ្ធភាពទាំងអស់ ដែលអាចចាំបាច់ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងការការពារបុគ្គលដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង

*ដោយហេតុថា* មាត្រា ២៤ នៃ**កិច្ចព្រមព្រៀង**ចែងបន្ថែមទៀតថា អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទទួលខុសត្រូវលើសន្តិសុខរបស់ជនជាប់ចោទ ដោយមិនគិតថាតើ ជនជាប់ចោទបង្ហាញខ្លួនដោយស្ម័គ្រចិត្តនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ឬមួយក៏ត្រូវចាប់ខ្លួននោះឡើយ

*ដោយហេតុថា* មាត្រា ១៧(ង) នៃ**កិច្ចព្រមព្រៀង**ចែងថា អង្គការសហប្រជាតិត្រូវទទួលខុសត្រូវលើការរៀបចំសុវត្ថិភាព និងសន្តិសុខ ដោយមានការព្រមព្រៀងគ្នាដោយឡែក រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា

*ដោយហេតុថា* រាជរដ្ឋាភិបាលកម្ពុជា បានបញ្ជាក់ថា អនុលោមតាមការទទួលខុសត្រូវរបស់ខ្លួន យោងតាមមាត្រា ១៤ នៃ**កិច្ចព្រមព្រៀង** រាជរដ្ឋាភិបាលនឹងផ្តល់ ដោយរ៉ាប់រងការចំណាយដោយខ្លួនឯង សម្រាប់រយៈពេលនៃ**កិច្ចព្រមព្រៀង** នូវផ្នែកខ្លះនៃ អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ នៅភូមិអង្គ ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល ធ្វើជាអាគារសម្រាប់សហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល (តទៅនេះហៅថា "អាគារ")

*ក្នុងគោលបំណង*សម្រេចបាននូវកិច្ចព្រមព្រៀងបំពេញបន្ថែម ដែលត្រូវបានប្រមើលទុកនៅក្នុង មាត្រា ១៧ (ង) នៃ**កិច្ចព្រមព្រៀង**

*អាស្រ័យហេតុនេះ* អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាព្រមព្រៀងដូចខាងក្រោម៖

## មាត្រា ១
## ការទទួលខុសត្រូវចម្បងរបស់រដ្ឋាភិបាល

១. រាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលខុសត្រូវលើសន្តិសុខអាគារ និងលើសុវត្ថិភាព និងសន្តិសុខរបស់បុគ្គលទាំងអស់ ដែលមានចែងក្នុង**កិច្ចព្រមព្រៀង** លើកលែងតែក្នុងលក្ខខណ្ឌដែលមានការចែងយ៉ាងច្បាស់លាស់ផ្សេងពីនេះនៅក្នុងកិច្ចព្រមព្រៀបបំពេញបន្ថែមនេះ។

២.	លើកលែងតែក្នុងលក្ខខណ្ឌដែលកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ អាចចែងយ៉ាងច្បាស់លាស់ថា ការទទួលខុសត្រូវលើការរៀបចំសុវត្ថិភាព និងសន្តិសុខជាការទទួលខុសត្រូវរបស់អង្គការសហប្រជាជាតិ ពុំមានចំណុចណាមួយនៅក្នុងកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ ត្រូវបានយល់ថាវ៉ូចផុតតាមវិធីណាក៏ដោយពីការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាលអនុលោមតាមមាត្រា ២៥ នៃ**កិច្ចព្រមព្រៀង**ឡើយ។ ជាពិសេស ការទទួលខុសត្រូវរបស់រដ្ឋាភិបាលដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ មិនត្រូវយល់ថាប៉ះពាល់ ឬកាត់បន្ថយតាមវិធីណាក៏ដោយ ដល់វិសាលភាពទូទៅនៃការទទួលខុសត្រូវរបស់ខ្លួនយោងតាមមាត្រានោះឡើយ។

## មាត្រា ២

## ទស្សនៈនៃការទទួលខុសត្រូវលើសន្តិសុខរបស់អង្គការសហប្រជាជាតិ

ស្ថិតក្រោម និងអនុលោមតាមខ្លឹមសារទាំងឡាយនៃកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ អង្គការសហប្រជាជាតិត្រូវទទួលខុសត្រូវលើ៖

(ក)	ការបង្កើត ការគ្រប់គ្រង និងបទបញ្ជាលើ៖

(i)	ការរៀបចំសន្តិសុខនៅខាងក្នុងអាគារ និង

(ii)	ការរៀបចំការការពារផ្ទាល់ តាមការចាំបាច់ សម្រាប់បុគ្គលិកអន្តរជាតិ និង

(ខ)	ការធានាលើការអនុវត្តរបស់បុគ្គលិកអន្តរជាតិទាំងអស់តាមខ្លឹមសារនៃកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ នឹងជាមួយនឹងគោលការណ៍ និងនីតិវិធីសន្តិសុខ ដែលបានបង្កើតឡើង និងបទដ្ឋានដែលបានចេញ នៅក្នុងកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ។

## មាត្រា ៣

## គោលការណ៍ និងនីតិវិធីសន្តិសុខ

១.	អង្គការសហប្រជាជាតិត្រូវផ្តល់ប្រធានសន្តិសុខអន្តរជាតិម្នាក់ ដែលត្រូវទទួលខុសត្រូវលើ៖

(ក)	ការបង្កើតគោលការណ៍ និងនីតិវិធីសម្រាប់ការប្រព្រឹត្តិទៅនៃប្រតិបត្តិការសន្តិសុខ ក្នុងគោលបំណងធានាបាននូវ៖

(i)	សន្តិសុខផ្ទៃក្នុងអាគារ និង

(ii)	ការការពារផ្ទាល់សម្រាប់បុគ្គលិកអន្តរជាតិ

(ខ)	ការតាមដានការអនុវត្តគោលការណ៍ និងនីតិវិធីទាំងអស់នោះ និង

(គ)	ការចេញបទបញ្ជាចាំបាច់ដើម្បីធានាថា គោលការណ៍ និងនិតិវិធីទាំងអស់នោះត្រូវបានអនុវត្តតាម។

២.	អង្គការសហប្រជាជាតិត្រូវផ្តល់ផងដែរនូវអនុប្រធានសន្តិសុខអន្តរជាតិម្នាក់ ដែលត្រូវបំពេញតួនាទីជំនួសឱ្យប្រធានសន្តិសុខអន្តរជាតិ នៅពេលអវត្តមានរបស់គាត់។

៣.	បុគ្គលិកសន្តិសុខទាំងអស់ មិនថាជាតិ ឬអន្តរជាតិ ដែលបំពេញមុខងារដូចមានចែងក្នុងកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ ត្រូវទទួលយក គោរពតាម និងអនុវត្តគោលការណ៍ និងនីតិវិធីដែលត្រូវបានបង្កើតឡើង និងបទបញ្ជាដែលចេញដោយប្រធានសន្តិសុខអន្តរជាតិ អនុលោមតាមកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ។

៤.	រដ្ឋាភិបាលត្រូវផ្តល់ប្រធានសន្តិសុខជាតិមួយរូប ដែលត្រូវទទួលខុសត្រូវលើ៖

(ក)	ការរៀបចំ និងការគ្រប់គ្រងប្រតិបត្តិការសន្តិសុខសម្រាប់គោលបំណងនៃការធានា៖

(i)	សន្តិសុខផ្នែកខាងក្រៅអាគារ និង

(ii)	ការការពារផ្ទាល់សម្រាប់បុគ្គលិកជាតិ

(ខ)	ការគ្រប់គ្រង និងការសម្របសម្រួលប្រតិបត្តិការរបស់បុគ្គលិកសន្តិសុខជាតិ ដែលបានផ្តល់ដោយរដ្ឋាភិបាល អនុលោមតាមកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ។

(គ)	តាមដានការអនុវត្តរបស់បុគ្គលិកសន្តិសុខជាតិទាំងអស់នោះ នូវគោលការណ៍ និងនីតិវិធីដែលបានបង្កើត និងបទបញ្ជាដែលបានដាក់ចេញ ដោយប្រធានសន្តិសុខអន្តរជាតិ អនុលោមតាមកថាខណ្ឌ ១ នៃមាត្រានេះ ក្នុងគោលបំណងធានាសន្តិសុខផ្នែកក្នុងរបស់អាគារ និងការការពារផ្ទាល់របស់បុគ្គលិកអន្តរជាតិ។

(ឃ)	ការចេញការណែនាំចាំបាច់ទៅកាន់បុគ្គលិកសន្តិសុខជាតិទាំងអស់នោះ ដើម្បីធានាថា គោលការណ៍ នីតិវិធី និងបទបញ្ជាទាំងអស់នោះ ដូចមានរៀបរាប់ក្នុងកថាខណ្ឌរង (គ) ត្រូវបានគោរពតាម។

៥.	ចៅក្រម សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា ប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិកទាំងអស់ដែលធ្វើការជាមួយសហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល ត្រូវទទួលយក និងគោរពតាមការទទួលខុសត្រូវរបស់ខ្លួន ដូចត្រូវបានកំណត់នៅក្នុងគោលការណ៍ និងនីតិវិធីដែលបានបង្កើត ដោយប្រធានសន្តិសុខអន្តរជាតិ អនុលោមតាមកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ។ ពួកគេក៏ត្រូវគោរពតាមបទបញ្ជា ដែលអាចត្រូវបានចេញចំពោះពួកគេផងដែរ អនុលោមតាមគោលការណ៍ និងនីតិវិធីទាំងអស់នោះ តាមរយៈបុគ្គលិកសន្តិសុខដែលបំពេញតួនាទីដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ។ អគ្គលេខាធិការនៃអង្គការសហប្រជាជាតិត្រូវចេញសេចក្តីណែនាំចាំបាច់សម្រាប់គោលបំណងនេះ ទៅកាន់ចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ និងអនុប្រធានការិយាល័យរដ្ឋបាល និង តាមរយៈអនុប្រធានការិយាល័យរដ្ឋបាល ទៅកាន់បុគ្គលិកអន្តរជាតិទាំងអស់ដែលធ្វើការជាមួយសហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល។ រដ្ឋាភិបាលត្រូវចេញសេចក្តីណែនាំចាំបាច់សម្រាប់គោលបំណងនេះ ទៅកាន់ចៅក្រមជាតិ សហចៅក្រមស៊ើបអង្កេតជាតិ សហព្រះរាជអាជ្ញាជាតិ និងប្រធានការិយាល័យរដ្ឋបាល និង តាមរយៈប្រធានការិយាល័យរដ្ឋបាល ទៅកាន់បុគ្គលិកជាតិទាំងអស់ដែលធ្វើការជាមួយសហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល។

៦.	ប្រធានសន្តិសុខអន្តរជាតិ ត្រូវធ្វើការក្រោមការគ្រប់គ្រងបច្ចេកទេសរបស់នាយកដ្ឋានសុវត្ថិភាព និងសន្តិសុខនៃអង្គការសហប្រជាជាតិ និងនៅក្នុងការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយមន្ត្រីដែលបានចាត់តាំងដោយអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា។

## <u>មាត្រា ៤</u>

## <u>ការរៀបចំផែនការសន្តិសុខ</u>

១.	អនុប្រធានសន្តិសុខអន្តរជាតិត្រូវទទួលខុសត្រូវ ក្រោមការដឹកនាំរបស់ប្រធានសន្តិសុខអន្តរជាតិលើ៖

(ក)	ការធ្វើការវាយតម្លៃតាមកាលកំណត់នៃហានិភ័យចំពោះសុវត្ថិភាព និងសន្តិសុខអាគារ និងបុគ្គលទាំងឡាយដែលមានចែងក្នុង**កិច្ចព្រមព្រៀង** និង

(ខ) បង្កើត និងរក្សាផែនការរួមសម្រាប់សន្តិសុខអាគារ និងមនុស្សទាំងនោះ។

២. រដ្ឋាភិបាល តាមរយៈប្រធានសន្តិសុខជាតិត្រូវផ្តល់អនុប្រធានសន្តិសុខម្នាក់ទទួលខុសត្រូវលើ៖

(ក) ការវាយតម្លៃទៀងទាត់ លម្អិត និងថ្មីៗ អំពីស្ថានការណ៍សន្តិសុខក្នុងប្រទេសកម្ពុជា និងការវិភាគលើទិសដៅសន្តិសុខ។

(ខ) ការរាយការណ៍ភ្លាមៗអំពីហេតុការណ៍ពាក់ព័ន្ធនឹងសន្តិសុខ។

(គ) ការជូនដំណឹងភ្លាមៗ តាមមធ្យោបាយលឿនបំផុតដែលអាចមាន អំពីព័ត៌មានណាមួយ ដែលបង្ហាញពីអត្ថិភាពដែលអាចកើតមាននៃការគំរាមកំហែងដ៏មានសក្តានុពលចំពោះអាគារ ឬដល់បុគ្គលិកអន្តរជាតិ ជាពិសេសចំពោះចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ ឬអនុប្រធានការិយាល័យរដ្ឋបាល។

៣. អនុប្រធានសន្តិសុខអន្តរជាតិ ត្រូវធ្វើការវាយតម្លៃហានិភ័យសន្តិសុខ និងផែនការសន្តិសុខ ក្នុងកិច្ចពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយប្រធានសន្តិសុខជាតិ។

៤. រដ្ឋាភិបាល តាមរយៈប្រធានសន្តិសុខជាតិ ត្រូវផ្តល់ឱ្យអនុប្រធានសន្តិសុខអន្តរជាតិ តាមការស្នើសុំនូវផែនទី និងព័ត៌មាន ទីតាំងដែលសង្ស័យ ឬដឹងថាមានគ្រាប់មីន គ្រាប់មិនទាន់ផ្ទុះ និងគ្រោះថ្នាក់ផ្សេងទៀត ដែលអាចមាននៅក្នុងតំបន់នានាក្នុងប្រទេសកម្ពុជា ដែលសមាជិកបុគ្គលិកជាតិឬអន្តរជាតិ ដែលធ្វើការជាមួយសហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ ការិយាល័យរដ្ឋបាល អាចធ្វើដំណើរទៅកាន់តំបន់ទាំងនោះ ក្នុងរយៈពេលនៃការបំពេញមុខងាររបស់ពួកគេ។

៥. អនុប្រធានសន្តិសុខអន្តរជាតិត្រូវចាត់វិធានការចាំបាច់ដើម្បីធានាការការពារព័ត៌មានសម្ងាត់ ឬព័ត៌មានរសើប ដែលបានផ្តល់ឱ្យគាត់ ដោយរដ្ឋាភិបាល។ អនុប្រធានសន្តិសុខអន្តរជាតិ និងប្រធានសន្តិសុខជាតិ ត្រូវរួមគ្នាបង្កើតពិធីសារសម្រាប់ការប្រាស្រ័យទំនាក់ទំនង ការដោះស្រាយ ការផ្សព្វផ្សាយ ការរក្សាទុក និង តាមការចាំបាច់ ការបំផ្លាញចោលព័ត៌មានសម្ងាត់ ឬព័ត៌មានរសើបបែបទាំងនោះ។

៦. អនុប្រធានសន្តិសុខអន្តរជាតិ ត្រូវផ្តល់ឱ្យប្រធានសន្តិសុខជាតិនូវការជូនដំណឹងភ្លាមៗអំពីព័ត៌មានណាមួយ ដែលគាត់អាចដឹងថាអាចនឹងមានអត្ថិភាពនៃការគំរាមកំហែងជាក់ស្តែង ឬដ៏មានសក្តានុពលចំពោះអាគារ ឬដល់បុគ្គលដែលមានចែងក្នុង**កិច្ចព្រមព្រៀង**។

## <u>មាត្រា ៥</u>

## <u>សន្តិសុខផ្ទៃក្នុងអាគារ</u>

១. អង្គការសហប្រជាជាតិត្រូវបានប្រគល់សិទ្ធិឱ្យគ្រប់គ្រងអាគារ រហូតដល់ និងរាប់បញ្ចូលទាំងបរិវេណជញ្ជាំងរបស់អាគារ ទាក់ទងនឹងបញ្ហាទាំងអស់ដែលពាក់ព័ន្ធនឹងសន្តិសុខរបស់អាគារ។ ការគ្រប់គ្រងបែបនេះត្រូវអនុវត្តដោយប្រធានសន្តិសុខអន្តរជាតិ ឬអ្នកតំណាងដែលត្រូវបានចាត់តាំងរបស់គាត់។

២. អង្គការសហប្រជាជាតិត្រូវផ្តល់មន្ត្រីត្រួតពិនិត្យអាគារអន្តរជាតិ ហើយរដ្ឋាភិបាលផ្តល់មន្ត្រីត្រួតពិនិត្យអាគារជាតិ ដែលទទួលខុសត្រូវរួមគ្នា ក្រោមការដឹកនាំរបស់ប្រធានសន្តិសុខអន្តរជាតិ សម្រាប់គ្រប់គ្រង និងដឹកនាំការរៀបចំសន្តិសុខផ្ទៃក្នុងសម្រាប់អាគារ។

៣. អង្គការសហប្រជាជាតិត្រូវបង្កើត ជ្រើសរើសបុគ្គលិក និងដំណើរការប្រព័ន្ធមួយសម្រាប់ការចេញ និងការត្រួតពិនិត្យបណ្ណសម្គាល់អត្តសញ្ញាណ និងស្លាកសម្គាល់ ទៅឱ្យអ្នកដែលត្រូវបានអនុញ្ញាតឱ្យចូលក្នុងអាគារ។ ប្រព័ន្ធបែបនេះត្រូវរួមបញ្ចូល ជាអាទិ៍ ការរៀបចំការចេញស្លាកសម្គាល់ជូនតំណាងរដ្ឋសមាជិកនៃអង្គការសហប្រជាជាតិ អគ្គលេខាធិការអង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និង

អន្តរជាតិ និងដល់សមាជិកប្រព័ន្ធសារព័ត៌មាន និងសាធារណជនទូទៅ ដែលមានបំណងចូលរួមសវនាការជាសាធារណៈរបស់អង្គជំនុំជម្រះវិសាមញ្ញ ដូចដែលមានចែងក្នុងមាត្រា ១២ កថាខណ្ឌទី ២ នៃ**កិច្ចព្រមព្រៀង**។ មានតែអ្នកដែលមានបណ្ណសម្គាល់អត្តសញ្ញាណ ឬស្លាកសម្គាល់ដែលមានសុពលភាព ដែលចេញឱ្យស្របតាមប្រព័ន្ធនេះប៉ុណ្ណោះ នឹងត្រូវបានអនុញ្ញាតឱ្យចូលក្នុងអាគារ។

៤. អង្គការសហប្រជាជាតិត្រូវបង្កើត ផ្គត់ផ្គង់បុគ្គលិក និងដំណើរការបន្ទប់ត្រួតពិនិត្យទីតាំង និងមណ្ឌលទំនាក់ទំនងសម្រាប់អាគារ។

៥. អង្គការសហប្រជាជាតិត្រូវបង្កើត ផ្គត់ផ្គង់បុគ្គលិក និងដំណើរការប្រព័ន្ធសម្រាប់ការចេញ និងការគ្រប់គ្រងកូនសោសម្រាប់ការិយាល័យនិងបន្ទប់ទាំងអស់នៅក្នុងអាគារ។

៦. រដ្ឋាភិបាលត្រូវផ្តល់បុគ្គលិកសន្តិសុខសម្រាប់គោលបំណង៖

(ក) ត្រួតពិនិត្យការចូលមកកាន់អាគារ។

(ខ) ការពិនិត្យមើលអ្នកដែលត្រូវបានអនុញ្ញាតឱ្យចូលមកកាន់អាគារ។

(គ) ធ្វើការល្បាតនៅក្នុងអាគារ។

(ឃ) ល្បាតបរិវេណជុំវិញអាគារ មកទល់ត្រឹមព្រំដែនជញ្ជាំង។

៧. រដ្ឋាភិបាលត្រូវផ្តល់មន្ត្រីទទួលបន្ទុកអគ្គីភ័យ និងសុវត្ថិភាពម្នាក់ ដែលត្រូវទទួលខុសត្រូវលើការបង្កើតផែនការសុវត្ថិភាពអគ្គីភ័យសម្រាប់អាគារ និងការកំណត់ និងអនុវត្តវិធានការ និងនីតិវិធីជាក់ស្តែងសម្រាប់ការការពារអគ្គីភ័យ និងសម្រាប់ការធានាសុវត្ថិភាពរបស់បុគ្គលទាំងឡាយនៅលើអាគារ ក្នុងករណីអគ្គីភ័យ ឬបញ្ហាបន្ទាន់ផ្សេងទៀត។

៨. រដ្ឋាភិបាលត្រូវផ្តល់បុគ្គលិកសន្តិសុខសម្រាប់គោលបំណងជាជំនួយដល់ការផ្គត់ផ្គង់បុគ្គលិក និងប្រតិបត្តិការនៃបន្ទប់ត្រួតពិនិត្យទីតាំង និងប្រព័ន្ធបណ្ណសម្គាល់អត្តសញ្ញាណ និងស្លាកសម្គាល់។

៩. បុគ្គលិកសន្តិសុខកម្ពុជាដែលបានផ្តល់ឱ្យអនុលោមតាមកថាខណ្ឌ ៦, ៧ និង ៨ ខាងលើ ត្រូវស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ និងការត្រួតពិនិត្យតាមខ្សែរបស់មន្ត្រីត្រួតពិនិត្យអាគារអន្តរជាតិ និងមន្ត្រីត្រួតពិនិត្យអាគារជាតិ និងស្ថិតក្រោមការគ្រប់គ្រង និងការដឹកនាំរួមរបស់ប្រធានសន្តិសុខអន្តរជាតិ តាមរយៈប្រធានសន្តិសុខជាតិ ទាក់ទងទៅនឹងបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងសន្តិសុខផ្ទៃក្នុងរបស់អាគារ។

## មាត្រា ៦

## សន្តិសុខផ្នែកខាងក្រៅអាគារ

១. រដ្ឋាភិបាលត្រូវទទួលខុសត្រូវការរៀបចំ និងការចាត់វិធានការចាំបាច់ខាងក្រៅអាគារដើម្បីធានាដល់សន្តិសុខរបស់អាគារ។ ការទទួលខុសត្រូវបែបទាំងនេះត្រូវអនុវត្តដោយប្រធានសន្តិសុខជាតិ ឬអ្នកតំណាងដែលត្រូវបានចាត់តាំងរបស់គាត់។

២. ប្រធានសន្តិសុខអន្តរជាតិ និងប្រធានសន្តិសុខជាតិ ត្រូវបង្កើតយុទ្ធសាស្ត្រ បច្ចេកទេស និងនីតិវិធីរួមគ្នា ដើម្បីទប់ស្កាត់ការចូលទៅក្នុងអាគារដោយគ្មានការអនុញ្ញាត និងសម្រាប់ការការពារប្រឆាំងនឹងការវាយប្រហារ ឬសកម្មភាពកលិយុគស៊ីវិល។

## មាត្រា ៧

## សេវាសង្គ្រោះបន្ទាន់

១. រដ្ឋាភិបាលត្រូវធានាថាសេវាកម្មខាងក្រោមរាល់តាមការហៅទូរស័ព្ទ គ្រប់ថ្ងៃទាំងអស់ និងគ្រប់ពេលវេលា និងម៉ោង មិនថាជាថ្ងៃធ្វើការ ឬម៉ោងធ្វើការ ឬផ្សេងពីនេះនោះឡើយ ក្នុងករណីបន្ទាន់ដែលកើតមានលើអាគារ ឬប៉ះពាល់ដល់អាគារ៖

(ក) រថយន្តពន្លត់អគ្គីភ័យ

(ខ) ការគាំពារវេជ្ជសាស្ត្រផ្នែកការប៉ះទង្គិចផ្លូវចិត្តនៅទីកន្លែងភ្លាមៗ

(គ) រថយន្តសង្គ្រោះបន្ទាន់

(ឃ) ការដោះបន្សាបគ្រាប់

(ង) កងកម្លាំងនគរបាលគ្រប់គ្រាន់ចាំបាច់សម្រាប់ការរក្សាច្បាប់ និងសណ្តាប់ធ្នាប់នៅក្នុងអាគារ និងសម្រាប់ការយកមនុស្សចេញ ប្រសិនបើចាំបាច់។

(ច) សមត្ថភាពឆ្លើយតបរហ័សគ្រប់គ្រាន់សម្រាប់បញ្ហាបន្ទាន់ក្នុងទម្រង់ណាមួយផ្សេងទៀត ដែលចាំបាច់ត្រូវមានការឆ្លើយតបរហ័ស ដែលអាចត្រូវបានកំណត់ក្នុងពេលរៀបចំផែនការសន្តិសុខ។

២. សេវាសង្គ្រោះបន្ទាន់ដែលមានចែងក្នុងកថាខណ្ឌ ១ អាចត្រូវបានស្នើសុំតែតាមរយៈប្រធានសន្តិសុខអន្តរជាតិឬតំណាងដែលត្រូវបានតែងតាំងរបស់គាត់តែប៉ុណ្ណោះ។ ប្រធានសន្តិសុខអន្តរជាតិត្រូវជូនដំណឹងប្រធានសន្តិសុខជាតិអំពីឈ្មោះរបស់តំណាងគាត់ ដែលត្រូវបានផ្តល់សិទ្ធិអំណាចក្នុងគោលបំណងនេះ។

៣. ប្រធានសន្តិសុខអន្តរជាតិ និងប្រធានសន្តិសុខជាតិត្រូវបង្កើតនីតិវិធីសម្រាប់ការប្រាស្រ័យទំនាក់ទំនង និងការដោះស្រាយសំណើសុំសេវាសង្គ្រោះបន្ទាន់។

## <u>មាត្រា ៨</u>

## <u>សន្តិសុខសាលសវនាការ</u>

១. អង្គការសហប្រជាជាតិត្រូវផ្តល់មន្ត្រីត្រួតពិនិត្យសន្តិសុខសាលសវនាការអន្តរជាតិ ហើយរដ្ឋាភិបាលត្រូវផ្តល់មន្ត្រីត្រួតពិនិត្យសន្តិសុខសាលសវនាការជាតិ ដែលត្រូវទទួលខុសត្រូវរួមគ្នា តាមការដឹកនាំរបស់ប្រធានសន្តិសុខអន្តរជាតិ លើការគ្រប់គ្រង និងការដឹកនាំការរៀបចំសន្តិសុខសម្រាប់សាលសវនាការ រួមមានជាអាទិ៍៖

(ក) ការត្រួតពិនិត្យបុគ្គលដែលមានបំណងចូលរួមសវនាការសាធារណៈរបស់អង្គជំនុំជម្រះវិសាមញ្ញ។

(ខ) ការត្រួតពិនិត្យសាលសាធារណៈក្នុងអំឡុងពេលសវនាការសាធារណៈបែបនោះ។

(គ) ការការពារបុគ្គលដែលមានចែងក្នុង**កិច្ចព្រមព្រៀង** ក្រៅពីជនជាប់ចោទ ខណៈដែលពួកគេស្ថិតនៅក្នុងសាលសវនាការ។

២. រដ្ឋាភិបាលត្រូវផ្តល់មន្ត្រីសាលសវនាការជាតិ ដែលត្រូវស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ និងការគ្រប់គ្រងតាមខ្សែរបស់មន្ត្រីត្រួតពិនិត្យសន្តិសុខសាលសវនាការអន្តរជាតិ និងមន្ត្រីត្រួតពិនិត្យសន្តិសុខសាលសវនាការជាតិ និងស្ថិតក្រោមការគ្រប់គ្រង និងដឹកនាំរួមរបស់ប្រធានសន្តិសុខអន្តរជាតិ តាមរយៈប្រធានសន្តិសុខជាតិ ទាក់ទងទៅនឹងបញ្ហាទាំងអស់ដែលពាក់ព័ន្ធនឹងសន្តិសុខសាលសវនាការ។

## <u>មាត្រា ៩</u>

## សន្តិសុខរបស់ជនជាប់ចោទ

១. លើកលែងតែក្នុងលក្ខខណ្ឌដែលមានចែងក្នុងកថាខណ្ឌខាងក្រោមនេះ រដ្ឋាភិបាលត្រូវទទួលខុសត្រូវគ្រប់ពេលលើសន្តិសុខ សុវត្ថិភាព និងសុខុមាលភាពរបស់ជនជាប់ចោទ រួមទាំងនៅពេលដែលពួកគេមានវត្តមាននៅក្នុងអាគារ និងនៅក្នុងសាលសវនាការ និងសម្រាប់ការត្រួតពិនិត្យពួកគេ ប្រសិនបើ និងខណៈពេលដែលស្ថិតក្រោមការចាប់ខ្លួន ឬការឃុំខ្លួន។

២. ប្រធានសន្តិសុខអន្តរជាតិ និងមន្ត្រីត្រួតពិនិត្យសន្តិសុខសាលសវនាការអន្តរជាតិ និងមន្ត្រីត្រួតពិនិត្យសន្តិសុខសាលសវនាការជាតិ តាមការដឹកនាំរបស់គាត់ ត្រូវទទួលខុសត្រូវលើការចាត់វិធានការចាំបាច់ដើម្បីធានាថាអាគារ រួមទាំងបន្ទប់ឃុំខ្លួន ផ្លូវ និងសាលសវនាការ មានសុវត្ថិភាព និងសន្តិសុខសម្រាប់ប្រើប្រាស់ដោយជនជាប់ចោទ។

៣. ប្រធានសន្តិសុខអន្តរជាតិ និងប្រធានសន្តិសុខជាតិត្រូវបង្កើតនីតិវិធីសម្រាប់ការធានាបាននូវការសម្របសម្រួលវិធានការសន្តិសុខប្រកបដោយប្រសិទ្ធភាពតាមផ្នែកនៃការទទួលខុសត្រូវរបស់ខ្លួន ទាក់ទងទៅនឹងការផ្លាស់ទីជនជាប់ចោទទៅកាន់ នៅក្នុង និងនៅក្រៅអាគារ រួមទាំងនីតិវិធីសម្រាប់ធានាថា ប្រធានសន្តិសុខអន្តរជាតិត្រូវបានផ្តល់ជូននូវការជូនដំណឹងជាមុនគ្រប់គ្រាន់ តាមរយៈបន្ទប់ត្រួតពិនិត្យអាគារ អំពីការផ្លាស់ទីបែបទាំងអស់នោះ។

## មាត្រា ១០

## ការការពារផ្ទាល់នៃបុគ្គលិកអន្តរជាតិ

១. អង្គការសហប្រជាជាតិត្រូវផ្តល់មន្ត្រីការពារផ្ទាល់អន្តរជាតិ ដើម្បីផ្តល់ការការពារផ្ទាល់ ដូចដែល និងនៅពេលដែលនាយកដ្ឋានសុវត្ថិភាព និងសន្តិសុខអង្គការសហប្រជាជាតិ មន្ត្រីដែលទទួលបានការចាត់តាំងដោយអង្គការសហប្រជាជាតិប្រចាំកម្ពុជា ឬប្រធានសន្តិសុខអន្តរជាតិ យល់ឃើញថាចាំបាច់ សម្រាប់ចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ និងអនុប្រធានការិយាល័យរដ្ឋបាល ក៏ដូចជាបុគ្គលិកអន្តរជាតិដែលធ្វើការជាមួយសហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល ដូចដែលនាយកដ្ឋានសុវត្ថិភាព និងសន្តិសុខអង្គការសហប្រជាជាតិ មន្ត្រីដែលទទួលបានការចាត់តាំងដោយអង្គការសហប្រជាជាតិប្រចាំកម្ពុជា ឬប្រធានសន្តិសុខអន្តរជាតិ អាចជួនកាលយល់ឃើញថាតម្រូវឱ្យមានការការពារផ្ទាល់។

២. បន្ទាប់ពីការស្នើសុំដោយប្រធានសន្តិសុខអន្តរជាតិ ប្រធានសន្តិសុខជាតិត្រូវផ្តល់មន្ត្រីការពារផ្ទាល់ជាតិបន្ថែមទៀត បន្ថែមលើការការពារផ្ទាល់លម្អិតជាផ្នែកមួយនៃមន្ត្រីការពារផ្ទាល់អន្តរជាតិ។ មន្ត្រីការពារផ្ទាល់ជាតិបន្ថែមទាំងនេះ បើទោះជាត្រូវបានចាត់តាំងទៅផ្នែកការពារផ្ទាល់លម្អិតក្តី ត្រូវអនុវត្តតាមការដឹកនាំ និងបទបញ្ជារបស់មន្ត្រីការពារផ្ទាល់អន្តរជាតិ ទទួលបន្ទុកភារកិច្ចលម្អិតដែលពួកគេត្រូវបានចាត់តាំង។ ប្រធានសន្តិសុខជាតិត្រូវចេញសេចក្តីណែនាំចាំបាច់សម្រាប់គោលបំណងនេះ ទៅកាន់មន្ត្រីការពារផ្ទាល់បន្ថែមដែលពាក់ព័ន្ធ។

៣. បន្ទាប់ពីការស្នើសុំដោយប្រធានសន្តិសុខអន្តរជាតិ ដែលបញ្ជូនតាមរយៈប្រធានសន្តិសុខជាតិ រដ្ឋាភិបាលត្រូវផ្តល់សន្តិសុខម្ភៃបួនម៉ោងសម្រាប់ទីកន្លែងរស់នៅរបស់បុគ្គលដែលត្រូវទទួលបានការការពារផ្ទាល់អនុលោមតាមកថាខណ្ឌ ១ នៃមាត្រានេះ។

៤. រដ្ឋាភិបាលត្រូវទទួលខុសត្រូវចំពោះការការពារផ្ទាល់របស់ចៅក្រមជាតិ សហចៅក្រមស៊ើបអង្កេតជាតិ សហព្រះរាជអាជ្ញាជាតិ និងប្រធានការិយាល័យរដ្ឋបាល អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជនុំជម្រះនិងការិយាល័យរដ្ឋបាល ដែលជួនកាលអាចតម្រូវឱ្យមានការការពារផ្ទាល់។ រដ្ឋាភិបាលក៏ត្រូវទទួលខុសត្រូវផងដែរលើការការពារទីកន្លែងរស់នៅរបស់ពួកគេ តាមការចាំបាច់។

## មាត្រា ១១

## វិធានការសន្តិសុខអង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិត្រូវផ្តល់អ្នកស៊ើបអង្កេតសន្តិសុខអន្តរជាតិម្នាក់ ដែលត្រូវទទួលខុសត្រូវលើបញ្ហាទាំងឡាយដែលប៉ះពាល់ដល់សន្តិសុខផ្ទាល់ខ្លួនរបស់ចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ អនុប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិកអន្តរជាតិដែលធ្វើការជាមួយសហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ ឬការិយាល័យរដ្ឋបាល រួមបញ្ចូល៖

(ក) ការពន្យល់សង្ខេប ការណែនាំ និងការធ្វើបច្ចុប្បន្នភាពពួកគេលើបញ្ហាដែលប៉ះពាល់ដល់សន្តិសុខផ្ទាល់ខ្លួនរបស់ពួកគេ។

(ខ) ការផ្តល់ឱ្យពួកគេនូវការបណ្តុះបណ្តាលទាក់ទងនឹងសន្តិសុខ។

(គ) ការរក្សាទុកនូវព័ត៌មានថ្មីៗអំពីទីកន្លែងស្នាក់នៅរបស់ពួកគេ និង

(ឃ) ការស៊ើបអង្កេតហេតុការណ៍ដែលពួកគេអាចជាប់ពាក់ព័ន្ធ រួមទាំងករណីដែលពួកគេជាជនរងគ្រោះនៃឧក្រិដ្ឋកម្ម

## មាត្រា ១២

## ព័ត៌មានសន្តិសុខ

១. អង្គការសហប្រជាជាតិត្រូវផ្តល់មន្ត្រីសន្តិសុខព័ត៌មានអន្តរជាតិ ដែលស្ថិតក្រោមការដឹកនាំរបស់ប្រធានសន្តិសុខអន្តរជាតិត្រូវទទួលខុសត្រូវលើ៖

(ក) ការអភិវឌ្ឍ ការបង្កើត និងការរក្សាគោលការណ៍ នីតិវិធី ពិធីសារ និងវិធានការសម្រាប់ការគ្រប់គ្រង ការត្រួតពិនិត្យ ការរក្សាទុក ការបញ្ជូន និងការកម្ទេច រាល់ព័ត៌មានទាំងអស់ដែលរក្សាទុកដោយអង្គជំនុំជម្រះវិសាមញ្ញ សហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល និងដោយបុគ្គលិកជាតិនិងអន្តរជាតិដែលធ្វើការជាមួយពួកគេ ក្នុងគោលបំណងធានាបាននូវសុចរិតភាពព័ត៌មាននោះ លទ្ធភាពអាចរកបានរបស់វាសម្រាប់ការប្រើប្រាស់ដែលត្រូវបានអនុញ្ញាត និងសន្តិសុខរបស់វាចំពោះការប្រើប្រាស់ដែលមិនត្រូវបានអនុញ្ញាត។

(ខ) ការត្រួតពិនិត្យការអនុវត្តតាមគោលការណ៍ នីតិវិធី ពិធីសារ និង វិធានការបែបទាំងនោះ និងការស៊ើបអង្កេតលើការរំលោភបំពាន។

(គ) ការស៊ើបអង្កេតការរំលោភលើសន្តិសុខព័ត៌មាន និងទំនាក់ទំនង។

(ឃ) ការកំណត់អត្តសញ្ញាណ និងការអនុវត្តវិធានការជាក់ស្តែង ដើម្បីការពារប្រព័ន្ធទំនាក់ទំនងនិងព័ត៌មានពីការវាយប្រហារព្យាបាទ ឬពីការជ្រៀតចូល ឬការប្រើប្រាស់ដោយគ្មានការអនុញ្ញាត។

(ង) ការផ្តល់ការណែនាំ និងការបណ្តុះបណ្តាលបុគ្គលិកដែលធ្វើការជាមួយអង្គជំនុំជម្រះវិសាមញ្ញ សហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល ទៅលើបញ្ហាពាក់ព័ន្ធនឹងសន្តិសុខព័ត៌មាន។

២. ក្នុងការបង្កើតគោលការណ៍ នីតិវិធី ពិធីសារ និងវិធានការដែលបានចែងក្នុងកថាខណ្ឌខាងដើម មន្ត្រីសន្តិសុខព័ត៌មានអន្តរជាតិ ត្រូវពិគ្រោះយោបល់ជាមួយចៅក្រម សហចៅក្រមស៊ើបអង្កេត សហព្រះរាជ

អាជ្ញា និងប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល ទាក់ទងនឹងភាពសម្ងាត់ លក្ខខណ្ឌតម្រូវនៃការចូលពិនិត្យ និងការប្រើប្រាស់ព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រង ឬកម្មសិទ្ធិរបស់ពួកគេរៀងខ្លួន។"

៣. ចៅក្រម សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា ប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិកទាំងអស់ដែលធ្វើការជាមួយសហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាលត្រូវទទួលយក និងអនុវត្តតាមគោលការណ៍ និតិវិធី ពិធីសារ និងវិធានការដែលបានបង្កើតឡើងដោយមន្ត្រីសន្តិសុខព័ត៌មានអន្តរជាតិ អនុលោមតាមកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ។ ប្រធាននិងអនុប្រធានការិយាល័យរដ្ឋបាលត្រូវចេញសេចក្តីណែនាំចាំបាច់សម្រាប់គោលបំណងនេះរៀងខ្លួន ទៅកាន់បុគ្គលិកជាតិនិងអន្តរជាតិដែលធ្វើការជាមួយពួកគេ។ អគ្គលេខាធិការអង្គការសហប្រជាជាតិ នឹងរដ្ឋាភិបាលក៏ត្រូវចេញសេចក្តីណែនាំចាំបាច់សម្រាប់គោលបំណងនេះរៀងខ្លួន ទៅកាន់ចៅក្រមជាតិនិងអន្តរជាតិ សហចៅក្រមជាតិនិងអន្តរជាតិ និងសហព្រះរាជអាជ្ញាជាតិនិងអន្តរជាតិ។

## <u>មាត្រា ១៣</u>

## <u>ការសម្របសម្រួល និងការទំនាក់ទំនង</u>

ប្រធានសន្តិសុខអន្តរជាតិ និងប្រធានសន្តិសុខជាតិ ត្រូវពិគ្រោះយោបល់គ្នាទៅវិញទៅមកយ៉ាងជិតស្និទ្ធ និងជាប្រចាំ ក្នុងគោលបំណងធានាបាននូវការសម្របសម្រួលការរៀបចំសន្តិសុខប្រកបដោយប្រសិទ្ធភាព នៅក្នុងផ្នែកនៃការទទួលខុសត្រូវរបស់ពួកគេរៀងខ្លួន យោងតាមកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ។

## <u>មាត្រា ១៤</u>

## <u>អាវុធ និងឯកសណ្ឋាន</u>

១. មន្ត្រីសន្តិសុខអង្គការសហប្រជាជាតិ និងមន្ត្រីការពារផ្ទាល់អន្តរជាតិ ដែលជ្រើសតាំងដោយប្រធានសន្តិសុខអន្តរជាតិ អាចកាន់កាប់ និងកាន់អាវុធ និងគ្រាប់រំសេវ ក្នុងពេលបំពេញភារកិច្ចផ្លូវការស្របតាមបទបញ្ជារបស់ខ្លួន។

២. មន្ត្រីសន្តិសុខអង្គការសហប្រជាជាតិ និងមន្ត្រីការពារផ្ទាល់អន្តរជាតិ អាចកាន់កាប់ និងស្លៀកពាក់សម្លៀកបំពាក់ការពារ រួមទាំង អាវក្រោះ ក្នុងពេលបំពេញភារកិច្ចផ្លូវការ។

៣. រដ្ឋាភិបាលត្រូវអនុញ្ញាតឱ្យអង្គការសហប្រជាជាតិនាំចូលអាវុធ គ្រាប់រំសេវ និងសម្លៀកបំពាក់ការពារ រួមទាំង អាវក្រោះ ដោយពុំគិតថ្លៃ និងពុំមានការរឹតត្បិតសម្រាប់ការប្រើប្រាស់ផ្លូវការរបស់មន្ត្រីសន្តិសុខអង្គការសហប្រជាជាតិ និងមន្ត្រីការពារផ្ទាល់អន្តរជាតិ។ អង្គការសហប្រជាជាតិ តាមរយៈប្រធានសន្តិសុខអន្តរជាតិ ត្រូវជូនដំណឹងរដ្ឋាភិបាលជាមុន តាមរយៈប្រធានសន្តិសុខជាតិ អំពីការនាំចូលសម្ភារៈបែបនោះ។

៤. ដោយពុំគិតថ្លៃ និងពុំមានការរឹតត្បិតណាមួយ រដ្ឋាភិបាលត្រូវទទួលយកការអនុញ្ញាត អាជ្ញាប័ណ្ណ និងលិខិតបញ្ជាក់ដែលចេញដោយអង្គការសហប្រជាជាតិសម្រាប់ការកាន់កាប់ ការដឹកជញ្ជូន និងការប្រើប្រាស់អាវុធ និងគ្រាប់រំសេវ។ ពុំមានការអនុញ្ញាត អាជ្ញាប័ណ្ណ និងលិខិតបញ្ជាក់ណាបន្ថែមទៀត ត្រូវបានតម្រូវសម្រាប់គោលបំណងទាំងនេះឡើយ។ ប្រធានសន្តិសុខអន្តរជាតិត្រូវជូនដំណឹងដោយពុំមានការពន្យារពេល ដល់រដ្ឋាភិបាល តាមរយៈប្រធានសន្តិសុខជាតិនូវរាល់ការអនុញ្ញាត អាជ្ញាប័ណ្ណ និងលិខិតបញ្ជាក់ដែលបានចេញដោយអង្គការសហប្រជាជាតិសម្រាប់ការកាន់កាប់ ការដឹកជញ្ជូន និងការប្រើប្រាស់អាវុធ និងគ្រាប់រំសេវ ដូចដែលនិងនៅពេលដែលការអនុញ្ញាត អាជ្ញាប័ណ្ណ និងលិខិតបញ្ជាក់ទាំងអស់ត្រូវបានចេញ។

៥. មន្ត្រីសន្តិសុខអង្គការសហប្រជាជាតិអាចស្លៀកពាក់ឯកសណ្ឋានអង្គការសហប្រជាជាតិ។ អនុលោមតាមកថាខណ្ឌ៦ ខាងក្រោម ពួកគេត្រូវអនុវត្តបែបនេះគ្រប់ពេលទាំងអស់ នៅពេលដែលកាន់អាវុធក្នុងពេលបំពេញភារកិច្ច។

៦. មន្ត្រីការពារផ្ទាល់អន្តរជាតិ និងមន្ត្រីសន្តិសុខអង្គការសហប្រជាជាតិ ដែលបម្រើការនៅក្នុងផ្នែកការពារផ្ទាល់លម្អិត អាចស្លៀកពាក់សម្លៀកបំពាក់ស៊ីវិល ដើម្បីបំពេញមុខងារផ្លូវការរបស់ខ្លួន។ ពួកគេអាចកាន់អាវុធ និងគ្រាប់រំសេវ និងស្លៀកពាក់សម្លៀកបំពាក់ការពារ រួមបញ្ចូលទាំងអាវក្រោះ ខណៈពេលដែលពួកគេត្រូវបានស្លៀកពាក់ដូច្នេះ សម្រាប់គោលបំណងនោះ។

៧. ប្រធានសន្តិសុខអន្តរជាតិត្រូវចាត់វិធានការចាំបាច់ ដើម្បីធានាបាននូវការដឹកជញ្ជូន ការថែទាំ ការរក្សាទុក និងការគ្រប់គ្រងអាវុធ និងគ្រាប់រំសេវបានត្រឹមត្រូវ។ រដ្ឋាភិបាលម្តងម្កាលអាចធ្វើការពិនិត្យដោយពុំមានការជូនដំណឹងជាមុន ដើម្បីពិនិត្យផ្ទៀងផ្ទាត់ និងបញ្ជាក់ថា មានការរៀបចំត្រឹមត្រូវរួចរាល់សម្រាប់គោលបំណងនេះ និងថាពួកវាកំពុងត្រូវបានអនុវត្តគួរជាទីពេញចិត្ត។

## <u>មាត្រា ១៥</u>

## <u>ឧបករណ៍សន្តិសុខ</u>

អង្គការសហប្រជាជាតិត្រូវផ្តល់ ដោយរ៉ាប់រងការចំណាយដោយខ្លួនឯង នូវសម្ភារៈឧបករណ៍សន្តិសុខដែលមានរៀបរាប់ក្នុងឧបសម្ព័ន្ធភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ។

## <u>មាត្រា ១៦</u>

## <u>ការផ្គត់ផ្គង់បុគ្គលិក</u>

បុគ្គលិកទាំងអស់ដែលបានផ្តល់ដោយអង្គការសហប្រជាជាតិ អនុលោមតាមកិច្ចព្រមព្រៀងបំពេញបន្ថែមនេះត្រូវជ្រើសរើស និងតែងតាំងដោយអនុប្រធានការិយាល័យរដ្ឋបាល អនុលោមតាមមាត្រា ៨ កថាខណ្ឌ ៣ នៃ**កិច្ចព្រមព្រៀង**។

## <u>មាត្រា ១៧</u>

## <u>ការទទួលខុសត្រូវ ការធានា និងការធានារ៉ាប់រង</u>

ភាគីនីមួយៗទៅនឹងកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ ត្រូវរ៉ាប់រងថ្លៃនិងការចំណាយដោយខ្លួនឯងទាំងស្រុង ត្រូវធានា លើកលែងការទទួលខុសត្រូវ និងការពារភាគីម្ខាងទៀត មន្ត្រី ភ្នាក់ងារ ឈ្នួល និងនិយោជិតរបស់ខ្លួន ពីនិងប្រឆាំងនឹងរាល់បណ្តឹង កិច្ចដំណើរការនីតិវិធី ការអះអាង ការទាមទារ ការបាត់បង់ និងការទទួលខុសត្រូវទាំងអស់នៃលក្ខណៈឬប្រភេទណាមួយ រួមបញ្ចូលទាំង ប៉ុន្តែមិនកំណត់ត្រឹមតែ ថ្លៃបណ្តឹងវិវាទ ថ្លៃមេធាវី ការចំណាយលើការដោះស្រាយវិវាទ សំណងខូចខាតទាំងអស់ និងថ្លៃនិងការចំណាយដែលពាក់ព័ន្ធទាំងអស់ផ្សេងទៀត ដែលផ្អែកលើ ដែលកើតចេញពី ដែលពាក់ព័ន្ធទៅនឹង ឬដែលមានទំនាក់ទំនងជាមួយអំពើសកម្ម ឬអកម្មណាមួយនៃភាគីធានា ឬបុគ្គលិកសន្តិសុខណាម្នាក់ ដែលបានផ្តល់ដោយភាគីធានា អនុលោមតាមកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ។

## <u>មាត្រា ១៨</u>
## <u>ការដោះស្រាយជម្លោះ</u>

ជម្លោះណាមួយរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការបកស្រាយ ឬការអនុវត្តកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ ដែលមិនអាចដោះស្រាយបានតាមរយៈការចរចា ឬទម្រង់នៃការដោះស្រាយដែលបានព្រមព្រៀង ត្រូវបញ្ជូនតាមសំណើរបស់ភាគីណាមួយស្នើសុំសេចក្តីសម្រេចស្ថាពរទៅកាន់ក្រុមប្រឹក្សាជំនុំជម្រះដែលមានសមាសភាពមជ្ឈត្តករបីរូប ក្នុងនោះមជ្ឈត្តករមួយរូបត្រូវតែងតាំង

ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ម្នាក់ទៀតត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា និងមជ្ឈត្តករទីបី ដែលត្រូវធ្វើជាប្រធាន ត្រូវជ្រើសរើសដោយមជ្ឈត្តករពីររូបដំបូង។ ប្រសិនបើភាគីណាមួយខកខានក្នុងការតែងតាំងមជ្ឈត្តករក្នុងរយៈពេល ៦០ ថ្ងៃ នៃការតែងតាំងដោយភាគីមួយផ្សេងទៀត ឬប្រសិនបើមជ្ឈត្តករទាំងពីររូបនេះមិនឯកភាពគ្នាក្នុងការជ្រើសរើសមជ្ឈត្តករទីបីក្នុងរយៈពេល ៦០ ថ្ងៃ នៃការតែងតាំងរបស់ខ្លួន ប្រធានតុលាការយុត្តិធម៌អន្តរជាតិ អាចធ្វើការតែងតាំងណាមួយដែលចាំបាច់ តាមការស្នើសុំរបស់ភាគីណាមួយក្នុងចំណោមភាគីទាំងពីរ។ ទោះជាយ៉ាងណា ជម្លោះណាមួយបែបនេះ ដែលពាក់ព័ន្ធទៅនឹងបញ្ហាចោទដែលបញ្ញត្តដោយអនុសញ្ញាស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់អង្គការសហប្រជាជាតិ ត្រូវដោះស្រាយអនុលោមតាមជំពូក ៣០ នៃអនុសញ្ញានោះ។

## មាត្រា ១៩
## បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ

មិនមានចំណុចណានៅក្នុង ឬទាក់ទងទៅនឹងកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ ត្រូវចាត់ទុកថាជាការបោះបង់ ដោយផ្ទាល់ ឬដោយតុណ្ហីភាព នៃបុព្វសិទ្ធិ ឬអភ័យឯកសិទ្ធិណាមួយរបស់អង្គការសហប្រជាជាតិ ឬនៃបុព្វសិទ្ធិ ឬអភ័យឯកសិទ្ធិណាមួយដែលមានចែងនៅក្នុង**កិច្ចព្រមព្រៀង**ឡើយ។

## មាត្រា ២០
## ការដកខ្លួនចេញពីកិច្ចសហប្រតិបត្តិការ

ក្នុងករណីដែលថា និងប្រសិនបើ អង្គការសហប្រជាជាតិអាចអនុវត្តសិទ្ធិរបស់ខ្លួនយោងតាមមាត្រា ២៨ នៃ**កិច្ចព្រមព្រៀង** ដើម្បីឈប់ផ្តល់ជំនួយ អនុលោមតាម**កិច្ចព្រមព្រៀង** នោះកាតព្វកិច្ចនានារបស់អង្គការសហប្រជាជាតិយោងតាមកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ ត្រូវឈប់អនុវត្ត។

## មាត្រា ២១
## ទំនាក់ទំនងជាមួយកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងបំពេញបន្ថែមនេះត្រូវបកស្រាយ និងអនុវត្តក្នុងលក្ខណៈមួយដែលស្របជាមួយនឹងពាក្យពេចន៍នៃ**កិច្ចព្រមព្រៀង**។

## មាត្រា ២២
## ការចូលជាធរមាន

កិច្ចព្រមព្រៀងបំពេញបន្ថែមនេះត្រូវចូលជាធរមានភ្លាមបន្ទាប់ពីចុះហត្ថលេខា។

## មាត្រា ២៣
## ការបញ្ចប់

កិច្ចព្រមព្រៀងបំពេញបន្ថែមនេះត្រូវនៅជាធរមានដរាបណា**កិច្ចព្រមព្រៀង**នៅជាធរមាន។ កិច្ចព្រមព្រៀងបំពេញបន្ថែមត្រូវបញ្ចប់នៅពេលដែល**កិច្ចព្រមព្រៀង**បញ្ចប់។

ធ្វើនៅភ្នំពេញនៅ __________ ឆ្នាំ២០០៦ ជាពីរច្បាប់ជាភាសាអង់គ្លេស។

| | |
|---|---|
| **ភាគីរាជរដ្ឋាភិបាលកម្ពុជា** | **ភាគីអង្គការសហប្រជាជាតិ** |
| *ហត្ថលេខា* | *ហត្ថលេខា* |
| **ឯក ឧត្តម ឯម សំអាន** | Michelle Lee |
| **រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជា** | **អនុប្រធានការិយាល័យរដ្ឋបាល** |

ប្រធាន
គណៈកម្មការសន្តិសុខអង្គជំនុំជម្រះវិសាមញ្ញ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ឧបសម្ព័ន្ធ

- ម៉ាស៊ីនថត X-ray ចំនួនពីរ(២)គ្រឿង
- ម៉ាស៊ីនថត X-ray ចំនួនមួយ(១)គ្រឿងសម្រាប់សាលសវនាការ
- ឧបករណ៍ត្រួតពិនិត្យពេលដើរចូល និងឧបករណ៍រាវរកលោហៈកាន់ដោយដៃចំនួនប្រាំបី(៨) គ្រឿង
- ឧបករណ៍ត្រួតពិនិត្យជាតិផ្ទុះកាន់ដោយដៃចំនួនមួយ(១)គ្រឿង
- ប្រព័ន្ធផ្សព្វផ្សាយទៅកាន់សាធារណជនមួយ(១) ដែលបានដាក់បញ្ចូលទៅក្នុងបន្ទប់ត្រួតពិនិត្យទីតាំង
- ប្រព័ន្ធទូរទស្សន៍សៀគ្វីបិទ(CCTV)មួយ(១) សម្រាប់អាគារ និងបរិវេណ ដែលត្រូវបានបញ្ចូលទៅក្នុងបន្ទប់ត្រួតពិនិត្យទីតាំង
- ប្រព័ន្ធត្រួតពិនិត្យបណ្ដាចេញចូលមួយ(១) ដែលត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធបណ្ណសម្គាល់អត្តសញ្ញាណ និងស្លាកសម្គាល់ និងក្នុងបន្ទប់ត្រួតពិនិត្យទីតាំង
- ប្រព័ន្ធប្រកាសសញ្ញាអាសន្នមួយ(១) ដែលត្រូវបានបញ្ចូលទៅក្នុងបន្ទប់ត្រួតពិនិត្យទីតាំង